ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០១៥៨ រ៉ថ.បនអ.ប្រក.

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

# ប្រកាស
# ស្ដីពី
# នីតិវិធីនៃការស្នើសុំនិងការផ្ដល់លិខិតអនុញ្ញាតសម្រាប់ការផ្ដល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលជូនអ្នកប្រើប្រាស់អគ្គិសនី

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៥ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

### ប្រការ ១._

កំណត់ឱ្យការស្នើសុំនិងការផ្ដល់លិខិតអនុញ្ញាត សម្រាប់នីតិបុគ្គលក្នុងការស្នើសុំលិខិតអនុញ្ញាតសម្រាប់ការផ្ដល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលជូនអ្នកប្រើប្រាស់អគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តទៅតាមនីតិវិធីដូចមានបង្ហាញក្នុងគំនូសបំព្រួញខាងក្រោម៖




**ប្រការ ២._**

"នីតិវិធីនៃការស្នើសុំ និងការផ្តល់លិខិតអនុញ្ញាតសម្រាប់ការផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលជូនអ្នកប្រើប្រាស់អគ្គិសនី" នេះមានគោលដៅដើម្បីលើកកម្ពស់ការគ្រប់គ្រងលើការផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជាឱ្យបានច្បាស់លាស់ មានប្រសិទ្ធភាព តម្លាភាព ស្មើភាពគ្នា គណនេយ្យភាព និងសមធម៌។ ទម្រង់លិខិតអនុញ្ញាតសម្រាប់ការផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅព្រះរាជាណាចក្រកម្ពុជាមានបង្ហាញក្នុងឧបសម្ព័ន្ធទី៣។ ទម្រង់លិខិតបដិសេធចំពោះការស្នើសុំលិខិតអនុញ្ញាត សម្រាប់ការផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅព្រះរាជាណាចក្រកម្ពុជាមានបង្ហាញក្នុងឧបសម្ព័ន្ធទី៤។

**ប្រការ ៣._**

អ្នកស្នើសុំ (នីតិបុគ្គល) ត្រូវបង់កម្រៃសេវាសាធារណៈសម្រាប់ការពិនិត្យ និងវាយតម្លៃលើសំណុំឯកសារនៃការស្នើសុំផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល ស្របតាមប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងរ៉ែ និងថាមពល។

**ប្រការ ៤._**

អង្គភាព និងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលរួមមាន៖ អគ្គនាយកដ្ឋានថាមពល មន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត និងអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវរួមគ្នាអនុវត្ត "នីតិវិធីនៃការស្នើសុំនិងការផ្តល់លិខិតអនុញ្ញាតសម្រាប់ការផ្តល់សេវាកម្មដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលជូនអ្នកប្រើប្រាស់អគ្គិសនី" ដែលបានដាក់ឱ្យអនុវត្តតាមប្រកាសនេះឱ្យបានសុក្រឹត និងមានប្រសិទ្ធភាព។

**ប្រការ ៥._**

នាយកខុទ្ទកាល័យ អគ្គនាយកដ្ឋានថាមពល មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត អាជ្ញាធរអគ្គិសនីកម្ពុជា និងអ្នកពាក់ព័ន្ធ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**កែវ_រតនៈ**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រដ្ឋបាលរាជធានី-ខេត្ត
- មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ